# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ មួន យ៉ាំ ភេទប្រុស អាយុ៥១ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ“និរសាកងពល១៨០”**

**ស្រុកកំណើតនៅភូមិកែងប្រាសាទ ឃុំសម្បួរ ស្រុកសម្បួរ ខេត្តក្រចេះ**

**សព្វថ្ងៃរស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឌី ខាំបូលី**

**០១:១៥ :៤៨**

**២៩ ទំព័រ**

បូលីៈ ពូឈ្មោះ មួន យ៉ាំ ពូ?

យ៉ាំៈ ទៅណាក៏ មួន យ៉ាំ ។

បូលីៈ អាយុប៉ុន្មានហើយពូ?

យ៉ាំៈ អាយុ៥២ហើយ! ៥១ ។

បូលីៈ ពូកើតឆ្នាំប៉ុន្មាន?

យ៉ាំៈ ឆ្នាំប៉ុន្មានទេ ឆ្នាំរោង ។

បូលីៈ នាគផង! កើតនៅភូមិឃុំអីពូ?

យ៉ាំៈ កើតនៅភូមិឃុំទួលកណ្ដាល ទេកែងប្រាសាទ ។

បូលីៈ ភូមិកែងប្រាសាទ ឃុំកែងប្រាសាទ ។

យ៉ាំៈ ឃុំសម្បួរ ។

បូលីៈ ហ៊ូ! ឃុំសម្បួរទេណ៊ា?

យ៉ាំៈ បាទ!

បូលីៈ ស្រុកសម្បួរ ខេត្តក្រចេះ?

យ៉ាំៈ បាទ! ខេត្តក្រចេះ ។

បូលីៈ នៅក្បែរនេះដែរ អ៊ឹប្រណី ស្គាល់ទេ?

យ៉ាំៈ និយាយមិនស្គាល់ ប៉ុន្តែហ៊ូ! ចាស់ៗទៅ ស្រុកនោះរកចាស់ៗដែលថាហៅទៅនេះ ហៅទៅនោះ រកមិនដឹងមួយណាមួយណី ។

បូលីៈ ឪពុកគាត់ម្ចាស់(ស្ដាប់ពុំបាន) ពូស្គាល់គាអី?

យ៉ាំៈ ស្គាល់នោះឯង! ស្គាល់ទាំងអស់នោះឯង ។

បូលីៈ ឪពុកគាត់មេស្រុក ឈី គាត់(ស្តាប់ពុំបាន) មានតែមួយម្ចាស់ហ្នឹងឯង មេស្រុកឈីហ្នឹង ។ ហើយកូនចៅគាត់មាន ប្រណី ប្រពៃ សួស្តី វង្សីនោះចាំទេពូ?

យ៉ាំៈ ចាំ! ប៉ុន្តែទៅស្រុកនោះឃើញគេប្លែកៗ គេហៅទៅនេះ គេហៅទៅនោះ ។

បូលីៈ អត់ចាំមុខទេ?

យ៉ាំៈ អត់ចាំមុខ ។

បូលីៈ ចាំណាបើ២០ ទៅ៣០ឆ្នាំហើយ ។

យ៉ាំៈ វាចូល៤០ហើយ ។

បូលីៈ ៤០ហើយ តាំងពីចេញមក ។

យ៉ាំៈ វាល្បាក់៤០វាតាំងពី៧៧,៧៦ ។ បែកគ្នាតាំងពី៧៦ បែកផ្ទះ នៅសណ្តាន់គិច នៅស្ពឺ សម្រោងគិច ឡូចល័យដាប់ គេជារុញទៅស្រុក ទៅប្រជុំនៅស្រុក ។ គែថាដក មីដែង តែម្នាក់ឯង មិនដឹងទៅណាទេ រាប់អ៊ូ! ទៅក្រចេះ បាន៤ទៅ៥ថ្ងៃ រៀនៗ ក៏គេឲ្យទៅព្រំដែនតែម្តង ។

បូលីៈ ហើយពូចូលបដិវត្តន៍តាំងពីឆ្នាំណាមក?

យ៉ាំៈ តាំងពី៧៦ ។

បូលីៈ ៧៦? មិនមែន៧០ទេអី?

យ៉ាំៈ ហ៊េ! មិនមែន៧០ទេ,៧៦ ។

បូលីៈ រដ្ឋប្រហារឆ្នាំ៧០ ។ ពេលហ្នឹងពូនៅណា រដ្ឋប្រហារហើយ?

យ៉ាំៈ អើ! នៅកុមារ ។

បូលីៈ នៅកែងប្រាសាទហ្នឹង ។ នៅជាមួយឪពុកម្តាយ?

យ៉ាំៈ នៅជាមួយឪពុកម្តាយ បែកពីឪពុកម្តាយ ទោះបីយប់ក្តី ជួនការឃើញមុខ ឪពុកម្តាយមួយភ្លែតៗទៅ ។ ហើយឪពុកខ្ញុំឈ្មោះ តាខេៗនោះ មានស្អីគេហៅទីនេះ គេហៅទៅនោះ.

បូលីៈ ឈ្មោះអីខេ?

យ៉ាំៈ មួនខេ!

បូលីៈ ចុះម្តាយពូ?

យ៉ាំៈ ហូរ វេន ។

បូលីៈ ស្គាល់ឈ្មោះហ្នឹងទេ?

អ្នកជិតខាងៈ ស្គាល់តា! ទៅលេងយាយ ។

បូលីៈ គាត់នៅទេរាល់ថ្ងៃ?

យ៉ាំៈ នៅ! ប៉ុន្តែមីប្អូនថា ១ថ្ងៃគាត់ មួយថ្ងៃកោហូបតែបបរហ្នឹង ចឹងថាប្រឹងបានធ្វើចម្រូងនេះហើយទៅតែម្តង ។

បូលីៈ គាត់អាយុប៉ុន្មានហើយ?

យ៉ាំៈ អាយុប្រហែលជា៨០ជាង ។

បូលីៈ ម្តាយ?

យ៉ាំៈ ម្តាយ ។

បូលីៈ ចុះតា?

យ៉ាំៈ អាយុកាលគាត់ស្លាប់ហ្នឹង ៩០ជាង ។

បូលីៈ ហ៊ូ! បានវែងណាស់?

យ៉ាំៈ ពីដើមគាត់ធ្វើអី ។

បូលីៈ ពីដើមនោះពីណាក៏ស្គាល់ដែរ ហើយនៅវត្ត?

យ៉ាំៈ វត្តសម្បូរ ។

បូលីៈ វត្តសសរ១០០?

យ៉ាំៈ បាទ! គាត់កសាងវត្ត ។ គាត់ទៅប្រជុំ រាយអង្គៀសកន្លះខែ មួយខែអី ហើយហ៊ុនសែននេះក៏ស្គាល់ដែរ គាត់ក៏ទំនាក់ទំនងដែរ យកមកធ្វើវត្តហ្នឹង កសាងវត្តជិតហើយ ទទួលគាត់នោះស្លាប់ ។

បូលីៈ ឈ្មោះតាខេ?

យ៉ាំៈ បាទ ។

បូលីៈ ពីណាក៏ស្គាល់ដែរចឹង?

យ៉ាំៈ ពីណាស្គាល់ដែរ! តាំងពីអាមេរិក តាំងពីអូស្ត្រាលី មកយកកាសែតយកអី ផាប់ប៉ុន្មាន ផាប់ជាង២០ឆ្នាំ ទៅហើយ មករាយអង្គៀសនៅកាសែតទៀត ។

បូលីៈ កាសែត?

យ៉ាំៈ កាសែតស្នូតយើងហ្នឹង ។ មកពីអូស្ត្រាលី មករកកាសែតទៀត! មាននៅសេសសល់ទេកាសែតសេសសល់អីប្អូនខ្ញុំវាពួកគេចាក់ឯណាហើយ វាសុំគេមកវាយចោល អត់ឲ្យពួសម្ទេង ពួអីទេថាគាត់នៅរស់ ។ រាល់ថ្ងៃហ្នឹង ឪពុកវាអត់មានថាស្លាប់ទេ បងប្អូនសព្វថ្ងៃទៅធ្វើការជាមួយក្រុមហ៊ុនទាក់ទងគ្នា ហើយជូនកាលកន្លះឆ្នាំបានគាត់មក ។

បូលីៈ នរណាគេ?

យ៉ាំៈ ឪពុកខ្ញុំ ។ សម័យនេះគេកសាងវត្តហ្នឹង ។

បូលីៈ ឆ្នាំ៩០ជាងហើយទេណ៎ពូ?

យ៉ាំៈ ៩០ជាងហើយ ។

បូលីៈ អាហ្នឹងក្រោយខ្មែរក្រហមហើយតិចចឹង?

យ៉ាំៈ បាទ!

បូលីៈ ចុះបងប្អូនពូប៉ុន្មាននាក់ទាំងអស់?

យ៉ាំៈ ៦នាក់ ។

បូលីៈ ប្រុស! ប៉ុន្មានស្រីប៉ុន្មាន?

យ៉ាំៈ ប្រុស៣ ស្រី៣ ។

បូលីៈ ស្មើរតែម្តង! ហើយពូកូនទីប៉ុន្មាន?

យ៉ាំៈ កូនទី៤ ។

បូលីៈ កូនទីឈ្មោះអីគេកូនទី១?

យ៉ាំៈ ទី១ គុំ!

បូលីៈ គុំ! ប្រុស ឬក៏ស្រី?

យ៉ាំៈ ស្រី ។

បូលីៈ នៅរស់ទេអ៊ឹ?

យ៉ាំៈ នៅ!

បូលីៈ នៅសម្បូរហ្នឹង?

យ៉ាំៈ បាទ!

បូលីៈ ហើយប្តីគាត់ឈ្មោះអីទៅ?

យ៉ាំៈ ឈ្មោះក្រា ។

បូលីៈ ចុះទី២?

យ៉ាំៈ ទី២ឈ្មោះ បងតាំង ។

បូលីៈ ប្រុស ឬក៏ស្រី?

យ៉ាំៈ ប្រុស ។

បូលីៈ ប្រពន្ធគាត់ឈ្មោះអីគេ?

យាំៈ ប្រពន្ធស្លាប់បាត់ហើយ ។ ស្លាប់ទាំងប្តីទាំងប្រពន្ធ ។

បូលីៈ គាត់ខូចពីអង្កាល់?

យាំៈ កាលដែលជំនាន់ឡើងលើភ្នំហ្នឹង ។

បូលីៈ គាត់ស្លាប់នៅលើភ្នំទេហ៎?

យាំៈ បាទ!

បូលីៈ គេធ្វើអីគេ?

យាំៈ (ស្តាប់ពុំបាន) ។

បូលីៈ ទី៣ ឈ្មោះអីគេ?

យាំៈ ឈ្មោះ យាង!

បូលីៈ ប្រុស ឬក៏ស្រី?

យាំៈ ប្រុស ហើយបានខ្ញុំ ។

បូលីៈ មួន យាងនៅទេ?

យាំៈ ស្លាប់ហើយ ។

បូលីៈ ស្លាប់ពីអង្កាល់?

យាំៈ ស្លាប់កាលសម័យ៧៩ ។

បូលីៈ លើភ្នំ ឬនៅឯណា?

យាំៈ ស្លាប់តាំងពីជំនាន់៧៩ អាគេរត់មកចុះឡើងៗ ប្រពាក់ប្រពួនគ្នា ក៏គេសម្លាប់ទៅអីទៅ ។

បូលីៈ អស់ពីរចឹងណ៎?

យាំៈ បាទ! អស់ពីរ ។

បូលីៈ បន្ទាប់មកទី៤ ពូ មួន យាំ?

យាំៈ បាទ!

បូលីៈ ទី៥ ។

យាំៈ សំដី ។

បូលីៈ ៤ សំដី! ហ៊ូ! ឈ្មោះសំដីចឹងតែម្តង?

យាំៈ ដីៗទេ គេហៅដីៗ

បូលីៈ ប្រុស ឬក៏ស្រី?

យាំៈ ស្រី ធ្វើពេទ្យ ។ ស្រុកសំបួរ!

បូលីៈ ឥលូវនៅសម្បូរឡើយទេ?

យ៉ាំៈ នៅសម្បូរ តែរល់ថ្ងៃហ្នឹង។

បូលីៈ ប្តីគាត់ឈ្មោះអីទៅ?

យ៉ាំៈ អត់ដឹងឈ្មោះអីទេ។

បូលីៈ ទី៦?

យ៉ាំៈ សុខទី។

បូលីៈ មួន សុខទី!

យ៉ាំៈ មួន សុខទី! ស្រីនៅដែរ ប៉ុន្តែប្តីគេថាទៅណា ទៅនៅឯអូរក្រូចមិនដឹង អីមិនដឹង។ គេក្រុមហ៊ុនគេ។ ខែមុននោះមកផែបនោះមកក៏ទៅវិញទៅ ទៅមណ្ឌលគិរី ទៅខាងខ្មែរគេ ហ៊ុនសែន ហ៊ុនតូច ហ៊ុនស្អីៗហ្នឹង។ ប៉ុន្តែជាប់សាច់ជាប់ឈាមគ្នាហ្នឹងណា យកគ្នាហ្នឹង អាណិតហើយនឹកឃើញថាឪពុកវាស្លាប់ វាយកទៅ។

បូលីៈ ហឺ! ពូរៀនបានថ្នាក់ទីប៉ុន្មានពីតូចៗមក?

យ៉ាំៈ ពីតូចៗមករៀនបានថ្នាក់ទីពាហ្នឹង! រដ្ឋចេះ! បើនៅដីថៃ ខ្ញុំរៀនទៀតហ្នឹង ខ្ញុំរៀនទៀត នែកសៀវភៅខ្ញុំ មកវាយឯណាអត់ចោលទេសៀវភៅ។

បូលីៈ នៅទេសៀវភៅ?

យ៉ាំៈ អត់រលីង តាំងពីខ្ញុំរបួសនោះ។ របួសហើយ ចោលអស់ហើយ! សៀវភៅស្អីៗ ថៃស្អីរៀនចេះសព្វគ្រប់ហើយថៃ ឥលូវសូម្បីតែខ្មែរក៏ភ្លេចដែរ។

បូលីៈ ម៉េចចឹង?

យ៉ាំៈ សរសេរប្រសាទ។ បើរៀនថៃចេះ! ចូលស្រុកថៃ ចូលស្រុកអីកាលដែលខ្ញុំនៅដើងជា ដៃជាចូលទៅស្រុកថៃ មាននរណាចាប់។

បូលីៈ ចេះថៃ?

យ៉ាំៈ ថៃ។ ហើយក្រមុំថៃវាចង់យកទៅ កុំអី ណាំ យឿននោះ! ទៅនៅណាំយឿនហ្នឹងឯង។ យកទៅ១អាទិត្យគេបញ្ជ្រៀនមួង ឈប់សម្រាកវាមក មកហ្នឹង បងឯងទៅ អាកូនគណៈខេត្តនោះអាប៊ុននោះ វាមក កុំអីទៅបាត់ ទៅឡូអាមួយនោះវាទៅ។ អាមួយនោះវានៅមន្ទីរ ដូចដែរ។ ឯងទៅមុនទៅ ឯងទៅយកគ្រាប់បែកមួយគ្រាប់ទៅ ការពារខ្លួន។ ប៉ុនយ៉ាងម៉េចម៉ា ទៅគេតាមមិញខ្ញុំ នៅវាយភ្នំឆត្រ័ហ្នឹង ខ្ញុំទៅវាយភ្នំឆត្រ័ហើយខ្ញុំមេគេជាមួយខ្ញុំខាងគេអូរ។ អង្គរខ្ញុំអត់ហានទៅ បើអត់គេអូរ គេលួចទៅបាត់។

បូលីៈ មករត់កាលពីយួនវាយមកដំបូង ពូរត់មកពីណា?

យ៉ាំៈ ម្តុំខេត្តពោធិ៍សាត់ បាត់ដំបង ជិតដល់ព្រំដែនបាត់ដំបង ។

បូលីៈ ប៉ុន ដំបូងបំផុតនៅវាលវែង?

យ៉ាំៈ បាទ!

បូលីៈ វាលវែងនៅច្រកអីគេ?

យ៉ាំៈ វាផ្លូវជាតិលេខ៥ ។

បូលីៈ កងពលលេខប៉ុន្មាន?

យ៉ាំៈ កងពលខេត្តក្រចេះ ។

បូលីៈ កងពលខេត្តក្រចេះ?

យ៉ាំៈ បាទ!

បូលីៈ កងពលអីគេទៅ?

យ៉ាំៈ ទេ! មិនដឹងកងពលយ៉ាងម៉េចគេទេ ។

បូលីៈ ខេត្តក្រចេះមានកងពលមួយ?

យ៉ាំៈ មានប៉ុន្មានកងពលទេ! វាពួកវ-១៥, វ-១៦ចូលទៀតបានបូកគ្នាទាំងអស់ហ្នឹង ។

បូលីៈ បាន១កងពល! មានចាំលេខកងពលទេកាលហ្នឹង?

យ៉ាំៈ អត់!

បូលីៈ ពីណាគេមេកងពល?

យ៉ាំៈ មិនដឹងពីណាទេ ហើយវរសេនាធំនោះ តានេះ តាអី តាពីន វរសេនាធំ ។

បូលីៈ តាពីន?

យ៉ាំៈ តាពីន! នៅខេត្តក្រចេះ ។

បូលីៈ កាលសម័យខ្មែរក្រហមពូនៅណា នៅក្រចេះ ឬក៏នៅឯណា?

យ៉ាំៈ នៅខេត្តក្រចេះ ។

បូលីៈ នៅម្តុំណា?

យ៉ាំៈ នៅទល់មុខយួននោះ ។

បូលីៈ នៅស្នួល?

យ៉ាំៈ នៅស្នួល ។ នៅស្អី ភ្លេចភ្លាំងអស់ហើយ! នៅវាលស្អី វាលចាន់ធូ ។

បូលីៈ ស្រុកស្នួល?

យ៉ាំៈ ស្រុកស្នួល ។ វាលចាន់ធូ ប៉ុន្តែព្រំប្រទល់យួន-ខ្មែរ ។

បូលីៈ គេឲ្យទៅវាយនៅហ្នឹង?

យ៉ាំៈ បាទ!

បូលីៈ ឆ្នាំប៉ុន្មាន?

យ៉ាំៈ ឆ្នាំ៧៧, ៧៨ ។ ៧៩ដាច់ តែម្តង! រត់តែម្តង ។

បូលីៈ កងពលលេខប៉ុន្មាន អាហ្នឹងនៅវាលចាន់ធូហ្នឹង?

យ៉ាំៈ អ៊ូ! បូកសរុបគ្នាច្រើនកងពលណាស់ ។

បូលីៈ ប៉ុនមានលេខប៉ុន្មានខ្លះ?

យ៉ាំៈ កងពលលេខ១៦ លេខ១៥ ហើយខេត្តក្រចេះ កងខេត្តក្រចេះ បូកសរុបគ្នា ៣ ទៅ៤កងពលនោះ ។

បូលីៈ កងខេត្តក្រចេះនោះកងពីណាគេ ពីណាគេមេកង?

យ៉ាំៈ មានពីណាគេ ទេភ្លេចភ្លាំងអស់ហើយ ។

បូលីៈ អាហ្នឹងដូចកងពល១១៧ នៅខេត្តក្រចេះហ្នឹង មានទេ?

យ៉ាំៈ ១១៧! ១៧ ផ្សេង ។

បូលីៈ ១៧ផ្សេង ។

យ៉ាំៈ ១១៧ផ្សេង គេរៀបក្រោយ ។ ១១៧!បាទ! មុនហ្នឹងគេថាកងនេះ១១០ កង១១០! កង១១០ហ្នឹង កងរៀបតាមពីមុន តាំងពីវាយសង្គ្រាម៥ឆ្នាំ កង១១០ ។

បូលីៈ កងពល ឬកងអីអាហ្នឹង?

យ៉ាំៈ កងពល ។

បូលីៈ កងពលរបស់ខាងណា?

យ៉ាំៈ របស់ខេត្តក្រចេះ ។

បូលីៈ គេកងពល១១០ចឹងតែម្តង?

យ៉ាំៈ បាទ!

បូលីៈ ពីណាមេកងពល?

យ៉ាំៈ ពីណាទេ មេកងពលនោះ! វាអត់ហ្នឹងចាំផង វាច្រើនតាកងពលវរសេនាតូចវរសេនាធំ ។

បូលីៈ ពូ នៅក្នុងកងពល១១០ហ្នឹងហេ៎?

យ៉ាំៈ ខ្ញុំនៅគេរៀបក្រោយទេ នៅក្នុងកងពល១១០ហ្នឹងឯង ចំណុះកងពល១១០ហ្នឹងឯង ។

បូលីៈ  វរសេនាធំលេខប៉ុន្មាន?

យ៉ាំៈ  វរសេនាធំវាអត់ចាំទៀត វាភ្លេចភ្លាំងអស់ហើយ ។

បូលីៈ  ចុះវរសេនាតូចលេខប៉ុន្មាន?

យ៉ាំៈ  អ៊ំ! វរសេនាតូចក៏ភ្លេច ភ្លេចភ្លាំងអស់ហើយ ។

បូលីៈ  គ្រាន់តែដឹងថាពូនៅកងពល១១០នោះ?

យ៉ាំៈ  បាទ!

បូលីៈ  ចឹងកងពល១១០ហ្នឹង នៅតំបន់ក្រចេះ?

យ៉ាំៈ  បាទ!

បូលីៈ  ក្រចេះទាំងមូលនរណាគេអ្នកគ្រប់គ្រង?

យ៉ាំៈ  ពីណាទេ! អ្នកគ្រប់គ្រងកាលនោះ ។

បូលីៈ  យី គួន?

យ៉ាំៈ  តាយីមិនដឹង! តាយី តាគួន មិនដឹង ។

បូលីៈ  តាយី តាគួន?

យ៉ាំៈ  បាទ! អាអ្នកគ្រប់គ្រងកាលពីជំនាន់នោះហ៎ អាជំនាន់សង្គ្រាម៥ឆ្នាំនោះ តាយី និងតាគួននោះ ឯង ហើយមួយជំនាន់នោះ ដល់អានេះក្រោយមកបានតាហឿន តាអីនេះឡើងទៅ ។

បូលីៈ  តាហឿនណា?

យ៉ាំៈ  តាហឿននៅត្រពាំងប្រាសាទរាល់ថ្ងៃ ។

បូលីៈ  ហ៊ូ! តាហឿននៅកងពល៦១២នេះណ៎?

យ៉ាំៈ  បាទ! ខ្ញុំនៅជាមួយគាត់ហ្នឹង ។

បូលីៈ  តាហឿនឡើងទៅធ្វើអី?

យ៉ាំៈ  ឡើងទៅកាន់កងពលខេត្តក្រចេះ ។

បូលីៈ  តាហឿនអ្នកកាន់ចឹង?

យ៉ាំៈ  បាទៗ!

បូលីៈ  ខាង១១០ហ្នឹងពូ?

យ៉ាំៈ  អត់ទេ! អា១១០នោះផ្សេង ។

បូលីៈ  ផលូវក្រចេះមានប៉ុន្មានកងពល?

យ៉ាំៈ  វាមាន៣ ទៅ៤កងពលនោះ ។

បូលីៈ ១១០មួយហើយណា ។

យាំុៈ ១១០គេរៀបតាំង ពីសង្គ្រាម៩ឆ្នាំ អាហ្នឹងកងពល១១០មួយ ។

បូលីៈ បន្ទាប់មក?

យាំុៈ បន្ទាប់មកគេរៀបច្រើន! ២ទៅ៣កងពលទៀត ។ ប៉ុន្តែវាភ្លេចភ្លាំងអស់ហើយ ។ ដល់ក្រោយមកខ្ញុំជួបនែក តាមអនុសេនាធំខ្ញុំរហូតដល់ មកដល់គាត់ដាច់ដៃដាច់ជើងនៅនេះឯង ។

បូលីៈ ពីណាគេ?

យាំុៈ បងផុន១ ។

បូលីៈ ផុនណាចេះ?

យាំុៈ ផុន! នៅនិរតីជាអ្នកនិរតីឡើងទៅស្រុកយើង ទៅខេត្តយើងនោះក៏គាត់ទៅវាយយួននោះក៏ជួបគ្នាក៏មកនៅក៏នៅជាមួយគាត់រហូត ។

បូលីៈ ចឹងកងពល១១០ពេលណាក៏រំលាយវាចោល?

យាំុៈ រំលាយចោល ខ្ទង់៧៩ ។ បែកបាក់គ្នា រំលាយចោល ។

បូលីៈ វាមានជីវិតបង្កើតតាំងពីឆ្នាំ៧០មក រហូតដល់៧៩តែម្តង?

យាំុៈ បាទ!

បូលីៈ ហើយពូចាំឈ្មោះមេកងពលទេ?

យាំុៈ អត់ទេ!

បូលីៈ ចុះតាហឿនដែលគាត់ទៅក្រចេះនោះគាត់ទៅឆ្នាំណា?

យាំុៈ ទៅក្រោយទេតាហឿន! ទៅ៧៨ទេដឹង!

បូលីៈ ពេលដែលវាយគ្នាខ្លាំងហ្នឹង?

យាំុៈ បាទ!

បូលីៈ តាហឿនទៅជួយខាងនោះ?

យាំុៈ ពេលថាខាងនោះក្បត់! ក្បត់អស់ហើយគេចាប់ គណៈ១ខេត្តយើងណាស់ក៏គេជូនគាត់ទៅ អស់តាផុន អស់តាហឿនតាអ៊ីនិរតី ។

បូលីៈ តាហៀនខាងនិរតីដែរ?

យាំុៈ បាទ

បូលីៈ តាហឿនទៅគាត់កាន់កងពលលេខប៉ុន្មាន?

យាំុៈ កាន់កងពលខេប៉ុន្មានទេអត់ចាំ ។

បូលីៈ បានន័យថាគាត់កាន់កងទ័ពខេត្តក្រចេះទាំងអស់ តាហឿនហ្នឹង?

យាំុៈ បាទ! គាត់ក្តោបក្តាប់មានសាខាអី ៤ទៅ៥នាក់ទៅណា ប៉ុនមិនដឹងពីណាខ្លះ?

បូលីៈ ទាល់តែមកដល់លើភ្នំនេះបានមកកាន់កងពល៦១២ ។

យាំុៈ បាទ!

បូលីៈ ហើយកងពល៦១២ហ្នឹង ចេញមកកងពលខេត្តក្រចេះហ្នឹងខ្លះទេមើលទៅ?

យាំុៈ បាទ! ខេត្តក្រចេះខ្លះ! ចង់ពាក់កណ្តាល ចុះគាត់មកពីក្រចេះដែរ ជាងពាក់កណ្តាលផង ។ ដល់នេះបានពួកមកចូលមកតាមខាងព្រះវិហារ ខាងអីតាមគោលមួយៗនៅ ។ មានតាហឿនហ្នឹងឯង ប៉ុនមិនដឹងតាមកងពលអី ។

បូលីៈ ចឹងតាំងពីពូចេញពីផ្ទះមកឆ្នាំ៧៦?

យាំុៈ ឆ្នាំ៧៦បែកពីម៉ែមក ជាមួយម៉ែពុកមក ។

បូលីៈ ៧៦ពូធ្វើអី?

យាំុៈ ៧៦ខ្ញុំនៅធ្វើស្រែ នៅធ្វើស្រែជាមួយម្តាយនៅរៀនខ្លះអីខ្លះទៅ ។ ល្ងាចឡើង ពេលម៉ែពិបាកពេកក៏រត់ទៅវាយសន្ទូច បន្តិចទៅមើលគោបន្តិចទៅមើលក្របីតិច ដល់យូរៗក្របីឲ្យទៅអីខ្ញុំដឹកលំបាកពេក ។ ឪពុកមានស្អីគាត់នៅវត្តហ្នឹង ចុះឡើងវត្តៗ ។

បូលីៈ ចុះប៉ុនពេលខ្មែរក្រហមគេបិទវត្ត បិទអី?

យាំុៈ បិទ! តែបិទមួយរយៈ ។ ប៉ុនគេថា វាមានគគាត់មិចក្មេចទេ គាត់នៅចាំជាប់ហ្នឹងឯង ហើយគេវាយស្អីៗក៏គាត់ជាមួយអាស្អីតាបែត អាស្អី! គាត់ហ្នឹងសឹងតែជិតតាបែតហ្នឹងឯង ។

បូលីៈ ចឹង? ឪពុកពូហ្នឹង?

យាំុៈ បាទ!

បូលីៈ ឪពូហ្នឹង កូនសិស្សរបស់តាបែត?

យាំុៈ បាទ!

បូលីៈ តាបែតគណៈស្រុកសម្បូរហ្នឹង?

យាំុៈ ពេលទៅម្តងៗ ទៅស្រែនោះហើយ ហើយវាធ្វើនេះធ្វើនោះដឹកអណ្តូងធ្វើទៅ ជីកអណ្តូងនៅស្រែនៅដាំដំណាំនោះ អឹហមទៅឯស្រែ បងនោះមិនដឹងជាស្អីទេ ទៅរកដីជញ្ជាត់ត្រី អាក្មេងៗនៅឯស្រែ ក្មេងៗមកខ្ញុំទៅហើយ ជញ្ជាត់ឲ្យអីនោះ បើថាត្រីទន្លេយើងនោះស៊ីអត់ឆ្ងាញ់ទេ ។ ហើយទៅអីលោមនោះទៅហើយ ទាល់តែយប់បានមកវិញទៅ ។

បូលីៈ ទៅរកត្រី?

យ៉ាំៈ ទៅដេកលេង ទៅមើលដំណាំ មើលអី អើពុកវាក៏គាត់ដឹកអណ្តូងហើយកូរអី វាមានចេកវា មានស្អី ទៀបដាំជាប់ហ្នឹងអីស្រែ ។

បូលីៈ ចឹងមើលទៅរស់ណៅដូចជាមិនតឹងតែងជាងកន្លែងផ្សេងៗទេ?

យ៉ាំៈ ទេ! អត់តឹងតែងទេ ។

បូលីៈ យើងហូបឯកជនបាន?

យ៉ាំៈ ហូបបាន! ខ្ញុំ៧៦នេះ ជិតចូល៧៧ ខ្ញុំនៅមន្ទីរចល័ត កងចល័តនៅឃុំយើងណា ។

បូលីៈ ឃុំសម្បូរ?

យ៉ាំៈ ឃុំសម្បូរ! ដល់នេះ ដល់បែកនេះហ្នឹងជិតនៅផ្ទះពីណាទេ! ជិតផ្ទះអាបូណានោះ ក៏ខ្ញុំរោងយាម ដេកនៅទីហ្នឹងឯង ។ សេះមួយគូ គេឲ្យសេះមួយគូចាំរត់សារឲ្យគេ យប់ថ្នាលណាទៅ ថ្នាលនេះ ឯង ។

បូលីៈ រត់សាទៅណា?

យ៉ាំៈ រត់សារសំបុត្រគេឲ្យពីស្រុកទៅ ឲ្យមកឃុំ ហើយមកគឃុំគេឲ្យទៅខ្ញុំរត់ទៅ ។

បូលីៈ កាលហ្នឹង គណៈស្រុកគេនៅម្តុំណា?

យ៉ាំៈ វានៅចល័តនោះ ផ្ទះខ្ញុំអត់មាននៅនេះទេ ផ្ទះខ្ញុំគេដាក់ជណ្តើរអស់ហើយបិទទ្វាហើយ ។

បូលីៈ ម៉េចចឹង?

យ៉ាំៈ ហើយចងសេះ អីនៅក្នុងនោះឯង ក្រោមផ្ទះហ្នឹងឯង ធ្វើក្រោលសេះហើយមនុស្សអត់នៅទេ ទៅនៅឯស្រែ ។ ម្នាក់ៗ គេទៅនៅឯស្រែនោះ អាខ្លះគេទៅនៅឯស្រែ អាខ្លះហ្នឹងឯង ប៉ុន ជាមួយម៉ែនៅតែម៉ែ ហ្នឹងប្អូនហើយហ្នឹងប្អូន ហើយហ្នឹងខ្ញុំចឹងឯង ។ ដល់អានេះខ្ញុំ ថាអើខ្ញុំមិន ដឹងយ៉ាងម៉េចយ៉ាងមាទេ ម៉ែ ។ មកដល់ឥលូវទៅយប់ម៉ោង១២នោះ ក៏គាត់ដាំបាយឲ្យហូប អត់ពិបាកទេ ។

បូលីៈ គណៈឃុំសម្បូរ ពីណាគេ?

យ៉ាំៈ ភ្លេចភ្លាំងអស់ហើយ ។

បូលីៈ អ្នកក្រចេះ ឬអ្នកណា?

យ៉ាំៈ អ្នកនៅក្រចេះហ្នឹងដែរ អ្នកនៅខេត្តយើងហ្នឹងដែរ ។

បូលីៈ មិនមែនអ្នកសម្បូរទេ?

យ៉ាំៈ អ្នកសម្បូរនោះឯង ។

បូលីៈ ពូអត់ចាំទេណ៎?

យាំុៈ   អត់ចាំទេ! បើក្មេចភ្លាំងអស់ហើយខ្ញុំ របួសត្រូវក្បាលសសៃប្រសាទនិយាយអត់ចេញទៀត ១ឆ្នាំ ។ អត់ចេះនិយាយ១ឆ្នាំ តែគេបង្រៀននិយាយ ។ បាននិយាប៉ុណ្ណេះ! ដល់(ស្តាប់ពុំបាន) ងិះងុះៗតា ។

បូលីៈ   គាត់នៅភូមិនា ឃុំសម្បូរហ្នឹង?

យាំុៈ   អ្នកភូមិសម្បូរមិនដឹង ។

បូលីៈ   ចុះតាចែតពូស្គាល់ច្បាស់ហើយតាចែតហ្នឹង ។ តាចែតនៅស្រុកណា តាចែតហ្នឹង?

យាំុៈ   មិនដឹងស្រុកណាទេ ប៉ុនមិនស្គាល់ស្រុកទេ ប៉ុន្តែខ្មោចឪពុកខ្ញុំស្គាល់ ។

បូលីៈ   ប៉ុន ឮសូរគេល្បីថាតាចែតហ្នឹង ខូចខាងស្រី ។

យាំុៈ   ហ្ហ៎! មួយសារៗបងនេះ សុទ្ធស្រីស្អាតៗហ្នឹង ក៏គេមន្ទីរអីហ្នឹង ឲ្យតែស្អាតតិចតាចែតចូលញឹក ហើយ ។ ចឹងណា! ញឹកចឹងឯង ។

បូលីៈ   មន្ទីរតាចែតនៅឯណា?

យាំុៈ   មន្ទីរក្មេចភ្លាំងអស់ហើយ ។

បូលីៈ   ខាងកោះខ្វែរទេ?

យាំុៈ   កោះខ្វែរ ហើយនឹងព្រៃព្រះមេរុ ។

បូលីៈ   ទៅលើសម្បូរទៀត?

យាំុៈ   បាទ! ព្រៃព្រះមេរុ ។

បូលីៈ   ចុះពូមានដឹងថាខ្មែរក្រហម វាយវត្តសសរ១០០ចោលទេ?

យាំុៈ   ហ្ហ៎! ខ្ញុំទៅនោះហើយ ។

បូលីៈ   ហ្ហ៎! ចឹងពូទៅបាត់ហើយ?

យាំុៈ   បាទ!

បូលីៈ   គេវាយយកសសរធំៗ មកធ្វើជើងស្ពានណ៎ា ។

យាំុៈ   ខ្ញុំទៅព្រាំដែនបាត់ហើយ!

បូលីៈ   បាទ!

យាំុៈ   ខ្ញុំឮគេនិយាយថារន្ទះបាញ់ខែប្រាំង ។

បូលីៈ   រន្ទះបាញ់ខែប្រាំង?

យាំុៈ   បាទ!  រន្ទះបាញ់ខែប្រាំង វត្តសម្បូរយើងនោះ ។

បូលីៈ   បាញ់មែន?

យាុំះ ហ៉ូ! របួសក៏របួសៗ ហើយឆាប់ក៏ឆាប់ ទទួលក្រណាត់សឡើងគ្រប់ រន្ទះបាញ់ឡើងកណ្ដាលថ្ងៃត្រង់នោះណា៎ៗ

បូលីះ រន្ទះបាញ់ ឬគ្រាប់កាំភ្លើងផ្ទោង?

យាុំះ អត់ទេ! រន្ទះបាញ់ៗ

បូលីះ ខែប្រាំងមានរន្ទះមកពីណាពូ?

យាុំះ ដឹង! ចឹងបានគេថាកុំសាកនឹងវត្តសម្បូរៗ

បូលីះ ហ៉ូ! ថាបារមីខ្មែរហ្នឹង?

យាុំះ បាទ! កំសាកវត្តសម្បូរបរមីក្រពុំឈូកចឹងណាៗ

បូលីះ ពូកែតែម្ដងណា?

យាុំះ បាទ!

បូលីះ ខែប្រាំងមានរន្ទះបាញ់ៗ

យាុំះ ខែប្រាំងមានរន្ទះបាញ់! សួរបងសាន សួរអី បងសៅអ្នកនៅនោះឯងបងសាននៅថ្នល់ បំបែកផ្ទះប្រកក្បឿងទល់មុខបន្ទាយបងភាពៗ

បូលីះ គាត់នៅក្រចេះដែរ?

យាុំះ គាត់នៅក្រចេះដូចគ្នាៗ

បូលីះ គាត់មកនៅហ្នឹងយូរហើយ?

យាុំះ បាទ! ខ្មែរក្រហមទាំងពីមុន!

បូលីះ ឥលូវពូដឹងថានៅម្ដុំៗពូអ្នកក្រចេះប៉ុន្មាននាក់ទេ?

យាុំះ អ្នកក្រចេះច្រើនណាស់ៗ ភឿន, រាយ រហូត!

បូលីះ សុទ្ធតែក្រចេះ?

យាុំះ សុទ្ធតែក្រចេះយើងហ្នឹងៗ មិនមែនអ្នកឆ្ងាយឯណា សុទ្ធតែនៅក្រចេះៗ

បូលីះ នៅទំនប់ដាច់នោះ នៅក្រចេះច្រើនណាស់ណា៎?

យាុំះ បាទ!

បូលីះ ហើយពូមកព្រំដែននោះពូមក កន្លែងវាលចាន់ធូទេ?

យាុំះ បាទ!

បូលីះ មកកងពល កាលនោះគាហៀនមកនៅៗទៅ?

យាុំះ មកហើយ! គាហៀនៗ

បូលី៖ គាហឿនមកហើយ ។

យាំ៖ ៧៨ គាហឿនមកហើយ ។

បូលី៖ បានន័យថាគេបញ្ជូនឲ្យមកជួយវាយព្រំដែន? កាលនោះគេរើស ឬពួស្ម័គ្រចិត្ត?

យាំ៖ ទេ! អត់ស្ម័គ្រចិត្តទេ គេរើស! កាលជំនាន់នោះមានទៅស្ម័គ្រចិត្តអី គេរើសតែម្ដង ។

បូលី៖ មុនពេលគេរើសហ្នឹង ពូធ្វើទាហានមែន?

យាំ៖ អត់ទាន់ធ្វើទាហានទេ ខ្ញុំនៅមន្ទីរ នៅមន្ទីរនិរសាហ្នឹងណា ។ រត់និរសាចុះឡើងៗ!

បូលី៖ និរសាឃុំហ៎?

យាំ៖ និរសាស្រុក ហើយហ្នឹងនិងនិរសាឃុំ ។ ស្រុកបន្ទាប់មក ដល់នេះក៏គេបញ្ជូនខ្ញុំទៅស្រុក ទៅស្រុកបាន២ថ្ងៃរៀន រៀនបាមពីរថ្ងៃ ក៏ទៅក្រចេះ ។ ទៅក្រចេះបាន៤ ទៅ១០ថ្ងៃ ឡើងទៅភូមិជាំស្រែ ។ ភូមិជាំស្រែហ្នឹង ឃុំមីងៗគេធ្វើស្រែហ្នឹង អ្នក១១០ ។

បូលី៖ កងពល១១០ ។

យាំ៖ កងពល១១០ហ្នឹង ខ្ញុំនៅកងពល១៨០ ។ ១១០,១៨០ ពីរកងពលហ៎!

បូលី៖ ហ៎ូ! ១៨០ មួយទៀត?

យាំ៖ គេរៀបកាលពីជំនាន់៥ឆ្នាំនោះ២កងពល ។ ១៨០,១១០ចឹងនោះបានដល់ក្រោយមកគេរៀបកងពល១១៧ ទៀត ។

បូលី៖ ១១៧យកកម្លាំងចេញពីណាមក?

យាំ៖ យកកម្លាំងចេញពីគ្រប់ភូមិ តាមភូមិគេរើស!

បូលី៖ មិនមែនយកពី១១០,១៣០ទេ?

យាំ៖ អត់ទេ! គេដើរតាមកងចល័តអី តាមចល័តឃុំ ចល័តស្រុកដកយកទៅតែម្ដង ។ ៧៨ហើយ!

បូលី៖ ចឹងអា១១៧បង្កើតឆ្នាំ៧៨ទេ?

យាំ៖ មានតែ២កងពលទេ បង្កើតឆ្នាំ៧០ ។ ហើយកងពល១១៧ហ្នឹងយកកម្លាំងចេញពីភូមិ ។

បូលី៖ ចេញពីភូមិទៅ?

យាំ៖ ឃុំ! ភូមិ ។

បូលី៖ ចឹងពូនៅណា ១១០ ឬក៏១៨០?

យាំ៖ ១៨០ ។

បូលី៖ ពូនៅ១៨០! ពីណាគេមេ១៨០?

យ៉ាំៈ មេនេះ! អត់ស្គាល់ទេប៉ុន្តែ មេប្រធានកងវរៈហ្នឹង គាស្អីទេងាប់បាត់ហើយ! ច្រើនតែងាប់ៗ នេះកងរយចឹងថា បងថានៅអន្លង់វែងនេះ គាត់ងាប់ហើយ គេបាញ់កាលព្រះប្រឡាយនេះ ។ គាត់ខ្លាំងពេក គាត់ធ្វើកងពលឡើងៗ នរណាក៏ហានដែរ ។ គាត់ហានទាំងអស់វាយទីណា មិនបែកគាត់ចូលដាក់បែកតែម្ដង ខ្ញុំនៅជាមួយគាត់រហូត៧៩បានមក៧៩ បានមកឡើងលើភ្នំ ។

បូលីៈ ពេលវៀតណាមវាយចូល៧៩ហ្នឹង ពូរត់ទៅណា?

យ៉ាំៈ ទៅស្រុក១៦ ភ្នំអន្លែប,

បូលីៈ ស្រុកអីគេបេះស្រុក១៦?

យ៉ាំៈ ស្រុកស្អីទេ! តទៅទៀតឱរ៉ាល់ នៅភ្នំឱរ៉ាល់ហ្នឹងឯង ។

បូលីៈ មិនមែនរត់ឡើងភ្នំទេ?

យ៉ាំៈ អត់ទេ! នៅភ្នំឱរ៉ាល់វាយប្រងាប់ប្រងិល តាមថ្នល់ជាត់លេខ៥នេះហ្នឹង ម្ដុំប្រាសាទបាកាន ប្រាសាទអីហ្នឹង ម្ដុំអីជិតទៅដល់ខេត្តនែកនេះមកដល់ខេត្តពោធិ៍សាត់ ស្រុកអន្លុរ ត្រឹមហ្នឹងហើយ ត្រឹមអន្លុរ ។

បូលីៈ ម៉េចក៏មិនទៅខាង ព្រះវិហារ១០០១ឬក៏១០០០ អីហ្នឹងវិញទៅ

យ៉ាំៈ ក្រោយមកចាំមើល ខ្ញុំ និយាយ ក្រោយមកនែ៎កបកទៅលើនោះវិញអាស្អីគេ តាម៉ុក មិនដឹងមេធំៗនោះ ។ នៅចូល ទៅវាយនៅហ្កាវ៉ាស់ នៅក្បត្រ នៅផ្លូវទះភ្លើងក៏វាយ វ៉ា ប្រណាក់វ៉ាសម្លែង វាយទាំងអស់ហ្នឹង ។ ទៅដល់នេះមក បានគេដកចេញ ដកពួកខ្ញុំមកទៅ នៅនេះទៅនៅអីស្រុកបារាយណ៍ ។

បូលីៈ បារាយណ៍ កំពង់ធំ?

យ៉ាំៈ បាទ! នៅបារាយណ៍កំពង់ធំ គិតទៅបួសរវល់តែយួនវាវាយ ទៅដល់ស្រុកបារាយណ៍នោះយួនវាយទៅក៏របួស ហើយក៏សែង មិនដែលដឹងទេកក្របីឆ្លងទៅក្រោយខាងនោះទន្លេម្ដុំខេត្តក្រចេះ យើងនៅនោះឯង យកក្រណាត់ឲ្យប្រជាជន១គីៗម្នាក់ ។

បូលីៈ ចឹងបែក៧៩ ភ្លាមពូមិនមែនរត់ឡើងភ្នំភ្លាមទេចឹង?

យ៉ាំៈ អត់ទេ!

បូលីៈ មកវាយនៅខាងក្នុងសិន?

យ៉ាំៈ បាទ! វាយទៅដល់ស្រុកបារាយណ៍នោះចូលអត់ចុះទេ ថ្ងៃមីន ថ្ងៃគ្រាប់ ថ្ងៃអី បៀតហ្នឹងមាត់ទន្លេ ស្រុកអើយជាប់ហ្នឹង ស្រុកព្រៃឈរ ទៅឆ្លងទៅខាងនោះ ចំការកៅស៊ូអីក៏នៅវាយនោះ ស៊ីក្តួចស៊ីចេកស៊ីអី ឡើងយ៉ាងម៉េច មកដល់នេះត្រៀមយើងត្រៀមអន្លុរ អន្លុរមួយថ្ងៃៗម្នាក់ ។

អង្ករទៅសុំប្រជាជនហ្នឹងឲ្យអង្ករមួយល្អីៗមក ធ្វើដំណើរមកភ្នំប្រាប់ប្រជាជននោះក៏មកកូនៗអើ ពិបាកណាស់នៅក្នុងព្រៃ បីសហ្នឹងចូលភូមិហើយតាខ្ញុំ បិសហៅឪពុកមកយកហើយតា ទៅដល់ នេះបើថាហៅពុកមកយកហើយចូលព្រៃ ចូលស្រុកបានរៀនបានសូត្រអីគេបាត់ ធ្វើអីៗគេ បាត់ហើយ ។ ឃើញអាបូនា បូអីហើយអាសុទ្ធតែបងប្អូនឯង សុទ្ធតែនាយកសាលាសុទ្ធតែ ស្អីៗម្នាក់ទៅ សុទ្ធតែថៃ ហៅគេឲ្យទៅស្អីរបស់គាត់អត់ គាត់អាណិតថ្លៃ ។

បូលី៖ ពេលពូនៅវាយក្នុងហ្នឹង ពូនៅកងពលលេខប៉ុន្មាន?

យ៉ាំ៖ កងពលជាមួយតាហឿននោះ ។

បូលី៖ ៦១២ ។ នៅជាមួយតាហឿនតាំងពីក្រចេះនោះមកយ៉ាងម៉េច?

យ៉ាំ៖ តាំងពីរត់មកតាំងពីក្រចេះ មករហូតទៅដល់លើភ្នំ តាំងពីបែកឥលូវនេះ បែកខ្ញុំរបួសនោះ ពិការឡើលើភ្នំនោះក៏ឲ្យទៅយកកម្លាំងវិញ ឲ្យទៅយកកម្លាំងវិញ មិនចេះឡើងលើភ្នំវិញទៀត ។ ទៅយកកម្លាំងពួកទន្លេ ព្រោះខ្ញុំមកកន្លះបានទៅយកកម្លាំងមក២ទៅ៣ អីទន្លេមេគង្គយើងនោះ ។

បូលី៖ ទន្លេមេគង្គ?

យ៉ាំ៖ បាទ!

បូលី៖ នៅខាងណា?

យ៉ាំ៖ នៅខេត្តក្រចេះ ។

បូលី៖ កម្លាំងហ្នឹងច្រើនអី?

យ៉ាំ៖ កម្លាំងច្រើន! កម្លាំងគេទាក់ទងគ្នាណា១០០នាក់ ឬក៏៥០នាក់ សម្រាក៤ទៅ៥០០នាក់ ឡើងមក ។

បូលី៖ ឡើងមកលើភ្នំ?

យ៉ាំ៖ បាទ! ដល់តែខ្ញុំរបួសហើយនេះបាន ខ្ញុំឈប់នៅជាមួយកុំអីតានេះយកទៅនៅជាមួយ ប៉ុន្តែកនៅ ឯលិចនោះតាឈាន ។

បូលី៖ តាឈាន?

យ៉ាំ៖ បាទ!

បូលី៖ កងពលលេខប៉ុន្មានហ្នឹង?

យ៉ាំ៖ កងពលលេខ២ដែរ ប៉ុន្តែបំបែក គាត់មកក្តាប់មួយរយៈហើយគាត់ទៅលិចវិញ ។ គាត់ទៅលិច វិញ គាត់ទៅខ្ញុំជានៅ! អាងហ្នឹងមកយកខ្ញុំវិញ ទៅយកទៅនៅជាមួយគាត់ ។

បូលីៈ ពូនៅវាយក្នុងនេះ អស់រយៈពេលប៉ុន្មានបានឡើងភ្នំ?

យ៉ាំុៈ អស់រយៈ៤ទៅ៥ឆ្នាំនោះ បានខ្ញុំមកភ្នំ។

បូលីៈ ឆ្នាំប៉ុន្មានបានពូឡើង?

យ៉ាំុៈ ដល់របួសឆ្នាំ៨៤ បានខ្ញុំឡើង។

បូលីៈ របួសនៅម្ដុំណា?

យ៉ាំុៈ របួសនៅកំពង់ធំ!

បូលីៈ ស្រុកបារាយណ៍។

យ៉ាំុៈ នៅស្រុកស្ទឹង! កំពង់ស្វាយ។

បូលីៈ កំពង់ស្វាយ!

យ៉ាំុៈ បាទ! អាព្រលានយន្តហោះចាស់នោះ ជិតាន់សីហនុទៅវាយឯទីហ្នឹងឯង។ ម៉ោង៧/ម៉ោង៨កណ្ដាលវាលព្រលាន វាយផ្លូវអាផ្លូវជាតិលេខ១២ទៅព្រះវិហារនោះទៅត្រៀមនៅនោះឯងដេក ដេកនឿល ស្មោសក់សេសនេះទៀត។ ដល់វាយបំបាក់មានបានយួនផង ព្រោះវាដឹកយកទៅ ព្រះវិហារ វាយកទៅព្រះវិហារឡើង៦ ទៅ៧ឡានក៏វាយខ្ទេចខ្ទីអស់ ខ្ទត់ខ្ទាយអស់ ក៏របួសខ្ញុំ។ របួសខ្ញុំថាមិនរស់ទេ ប្រជាជនថាមិនរស់ទេក៏កាប់មួយរណ្ដៅ។ ដល់ពេទ្យគេសែង១យប់ ១ថ្ងៃមកពេទ្យហើយគេកាប់១រណ្ដៅទៀត ចាំតែមើលទេ បីរណ្ដៅទេ។

បូលីៈ កាប់ទុកតែម្ដង?

យ៉ាំុៈ កាប់ទុក អត់មើលទេ! ដាក់តែសេរ៉ូមចោលទៅ។

បូលីៈ ម៉េចចឹង?

យ៉ាំុៈ ថាឆាប់ហើយ! បាត់ដង្ហើមអស់ហើយ។ ខ្លួនអីឡើងត្រជាក់អស់ហើយ! មានទៅស្អី។

បូលីៈ ហើយយ៉ាងម៉េចទៀតទៅ?

យ៉ាំុៈ ដល់នេះថ្ងៃពេញបូរមីហ្នឹង តាហឿននេះ គេផ្សង តាឈាននេះទៅទូរលេខថាឲ្យមើលវាឲ្យមើលវាឲ្យមេនទែន។ ពេទ្យណាក៏ដោយ កុំប្រហែស អស់ស្អីក៏អស់ទៅ ថ្នាំមិនបាច់ចាក់ទេ ឲ្យអ្នកជំងឺល្មមៗ កំបុតដៃ កំបុតជើងមិនបាច់ចាក់ទេ។ ៤ទៅ៥ថ្ងៃ ចាំចាក់មួយម្ជុលទៅ មើលវាឲ្យមែនទែន។ ថ្នាំពាម៉ែត្រ៤ជ្រុងថ្នាំ អើដឹកយកទៅមីង១យកទៅ ជំនួន១០០នាក់ដង។ ជញ្ជូនគ្រាប់ជញ្ជូនថ្នាំពេទ្យ ដាក់មុខផ្ទះមើលតែខ្ញុំទៅ ចាក់ទៅថ្នាំណាវាពិសេស ដាក់ទៅសុទ្ធតែអាសេរ៉ូមផ្កាស្វា អាសេរ៉ូមសាច់ព្យួរដៃផង ជើងផងបានជឹងខ្លួន។ ដឹងខ្លួនហ្នឹងខ្ញុំ ថ្ងៃពេញ

បូរមី គេថាខ្ញុំងាប់បាត់ហើយ ។ អត់ព្រួសម្ទេង ព្រួអីស្រែកផង អីអើផងក៏គេដេក អាខ្លះទៅ ១០០ម៉ែត្រ អាខ្លះទៅ២០០ម៉ែត្រ ពេទ្យវឿនព្យាបាលនោះហ៎ ។ អើយ! ងាប់ក៏ងាប់ទៅអា ធ្វើ ពេទ្យនោះនិយាយប្រាប់ដឹងខ្លួនហើយបង្រៀនពេទ្យនោះគ្រូបង្រៀនពេទ្យនោះភ្នំពេញ ផ្លូវធំផ្ដាំហើយ ពេទ្យវឿន ។

បូលីៈ ពេទ្យវឿន?

យ៉ាំៈ បាទ! ពេទ្យវឿន ។

បូលីៈ នៅឯណាផ្លូវ?

យ៉ាំៈ នៅភ្នំពេញ ។

បូលីៈ នៅពេទ្យណា?

យ៉ាំៈ មិនដឹងពេទ្យណា ព្រួថានៅភ្នំពេញនោះមានផ្ដាំហើយ ហើយពេទ្យនោះមិនមែននេះទេ ពេទ្យខ្មែរក្រហមជាំហ្នឹង ប៉ុន្តែគេសុទ្ធតែពេលងើបពីដេកហើយ លុប មុខលុបអីដុះធ្មេញ ពេទ្យនោះលុប ហើយអត់នេះទេ អើឃ្លានបាយស៊ីបាយ កន្ទុយបារីសៀតត្រចៀក ស៊ីបាយហើយបានទៅ លុបមុខនោះពេទ្យហ្នឹង មិនចេះឈឺគាត់ ។ ដល់នេះគាត់ថ្ងៃពេញបូរមី ថ្ងៃខែត្រង់ ទៅលេង អើយទៅលេង ទៅលេងលោកនៅមុំបីនោះ ។ ហើយលោកថាបានហើយ ឯងទៅវិញទៅក៏អត់ចង់ទៅដែរ ដល់លោកដេញឲ្យទៅវិញ ឯងមកធ្វើអី បានហើយអញទៅ អើ! បែកពីអញ៣ឆ្នាំ អញទៅលិចនោះ៣ឆ្នាំ ។ ក៏បកមកវិញដឹងខ្លួនតែម្ដង ដឹងខ្លួនទាល់តែសព្វថ្ងៃ គ្មាននរណាធ្វើអីទេ ។

បូលីៈ នៅពេទ្យហ្នឹង ពេទ្យនៅម្ដុំណា ពេទ្យព្យាបាលពូ?

យ៉ាំៈ ពេទ្យហ្នឹង ពេទ្យវឿននៅខ្មែរក្រហមយាមយើងហ្នឹង ។

បូលីៈ ប៉ុនមន្ទីរពេទ្យព្យាបាលហ្នឹងនៅខាងក្នុង ឬលើភ្នំ?

យ៉ាំៈ អត់ទេ! នៅលើភ្នំ ប៉ុន្តែគាត់ទៅតាមរៀបចំពេទ្យនៅក្នុង ។

បូលីៈ ពេទ្យនៅឯក្នុង?

យ៉ាំៈ បាទ!

បូលីៈ មានមន្ទីរពេទ្យដែរចឹង?

យ៉ាំៈ បាទ! រៀបចំពេទ្យពីក្នុងឡើងមនុស្ស៤ ទេ១០,២០នាក់ណាពេទ្យ ។

បូលីៈ មានមន្ទីរមានផ្ទះអីដែរ?

យ៉ាំៈ មានផ្ទះគេប្រក់ដេរខាន់មានោះណា ។ ផ្ទះប៉ុនៗហ្នឹង! វែងចងអង្រឹងនឹងគ្រែមួយៗរហូត ។

បូលីៈ យួនដូចអត់ឃើញ?

យ៉ាំៈ យួនម៉េចហានមក! នៅនេះស្អី ស្អីទេអូរប្រេកអាទៀន ត្រពាំងព្រីង ។

បូលីៈ ក្នុងស្រុកអីហ្នឹង?

យ៉ាំៈ ស្រុកស្មោង ។

បូលីៈ នៅក្នុងស្មោងតែម្តង?

យ៉ាំៈ បាទ!

បូលីៈ នៅស្មោងរកមិនឃើញណ៎?

យ៉ាំៈ អត់ហានមកទេ! យួន ។

បូលីៈ ក្បែរព្រះវិហារដែរស្មោង?

យ៉ាំៈ បាទ! ព្រំដែនវាជាប់ភ្នំដែក ជាប់ជាមួយព្រំព្រះវិហារ ព្រៃហ្នឹងវាធំគ្រាន់ដែរ ។

បូលីៈ ចឹងពូព្យាបាលនៅកន្លែងស្មោងហ្នឹង?

យ៉ាំៈ បាទ!

បូលីៈ ព្យាបាលប៉ុន្មានខែ បានជា?

យ៉ាំៈជិត១ឆ្នាំ! នៅស្មោងហ្នឹង ។

បូលីៈ អត់ឡើងមកស្មោងទេចឹង?

យ៉ាំៈ ដល់តែនេះ បានកងមេខ្ញុំ មកថាតាឈានអីតានេះ តាហឿននេះថាតាឯងយកវាមក សែងវាមក សែងខ្វះអីខ្វះទៅ ដើរអត់រួចទេជិត១ឆ្នាំហើយ ។ គេជិតកទៅមុជទឹក មុជអីស្គាល់រហូតហ្នឹង ។ ដល់តែនេះតាហឿនឲ្យតាឈាននោះ មកពីនោះថាឲ្យខ្ញុំទៅ ទៅដល់តាហឿនថា អត់ឲ្យទៅទេ ទៅសម្រាកនៅពេទ្យ មួយកងពល! នៅក៏នៅទៅ យកវានៅក៏នៅទៅ ។ ដល់តែយកវានៅក៏នៅទៅ តាញ៉ាន សុទ្ធតែអ្នកស្រុកក្រចេះយើង នៅមន្ទីរជាមួយគាត់ហ្នឹង ឯងព្យាបាលនិយាយជាមួយខ្ញុំឯងទៅហ៎ ។ ឯងដេកពេទ្យឲ្យជា បើមិនជាដៃជើងក៏ដោយ ឲ្យតែជារបួសឲ្យស្រួលបួលមកនៅមន្ទីរជាមួយអញ ។ អញយកមកនៅមន្ទីរជាមួយអញ គ្រប់គ្រងពួកអស់ហ្នឹង ។ ដល់ហើយខ្ញុំ អត់កើតទេចូលដើរទៅកេជូនទៅ ខ្ញុំបើកមើលសៀវភៅប្រវត្តិគាត់ណាទៅស៊ីញ៉ៅពីគាត់ហើយ ទៅចូលកន្លែងពេទ្យហ្នឹង ។ ទៅដល់ចូលកន្លែងពេទ្យបុសស្បូវជិតដីថៃហ្នឹងក៏ខ្ញុំថា កន្លែងពីការនៅទីណាចេះក៏ បើកមើលមន្ទីរពេទ្យក៏ស៊ីញ៉ៅៗ តិចទេ ប៉ុះតែបន្តិចទេហើយចូលកន្លែងពិការ ក៏ខ្ញុំនៅកន្លែងពិការរហូតទៅ ស៊ីញ៉ៅខ្លួនឯងតិចហ្នឹង ក្រឡៃខ្លួនឯង បន្តិចហ្នឹង ។ ខ្ញុំអត់អាបែកពីកូននៅជាមួយតាហឿននោះ ពិបាកណាស់ ។

បូលី៖ តាហឿន ជាមួយតាឈាន ពីណាគេមេ?

យ៉ាំ៖ តាឈានមេ ។

បូលី៖ តាហឿន អនុ?

យ៉ាំ៖ បាទ!

បូលី៖ ដល់ក្រោយមកបានតាហឿនមេ?

យ៉ាំ៖ បាទ! តាឈាននៅអី ជាមួយតាឌួនជាតាអីឯនោះ ទៅលិចកងការពារតាឌួនជាដកមួយកង វរខ្ញុំទៅ ទាំងអស់ អត់តែខ្ញុំទេ ចឹងហើយបានជាគេយកខ្ញុំទៅនោះ ទៅដល់ហ្នឹងគេនៅបរប៉ៃលិន នៅ ម៉ាឡៃនោះគេមានៗបានមើលឃើញយើងនៅដៃគ្នា ខ្ញុំវាមកលេងបងវានៅអូរម៉ាយ នេះ ។

បូលី៖ មិនមែនតាឈានទេ! អ៊ីឈានផ្សេង?

យ៉ាំ៖ បាទ!

បូលី៖ ចុះពូថាទៅវាយដល់អូរឆ័ត្រអីនោះឆ្នាំណាអាហ្នឹង?

យ៉ាំ៖ ភ្នំឆ័ត្រនៅឯនេះ! អី១០០២ ពី(ស្តាប់ពុំបាន) ។

បូលី៖ ភ្នំឆ័ត្រ! ១០០២អេ៎?

យ៉ាំ៖ បាទ! អីភ្នំឆ័ត្រ ។

បូលី៖ ក្រែងនៅបន្ទាយអំពិលនេះអីពូ?

យ៉ាំ៖ អត់ទេ! ១០០៣នេះតា ។ ភ្នំឆ័ត្រអីនោះ គេហៅភ្នំឆ័ត្រ អីជំនាន់នេះ ជំនាន់នែកជំនាន់ សង្គ្រាម៩ឆ្នាំ វាយភ្នំឆ័ត្រហ្នឹងអត់បែកទេ! គ្រាន់តែម៉ាស៊ីនអាឈើក៏នៅក្នុងនោះដែរ ឥលូវ! ហើយជំនាន់យួនក៏អីចឹងដែរ ។ វាចាប់ថៃមក ដាក់ឲ្យធ្វើប្រឡូកគូកធ្វើអីនៅចាក់បេតុងចាក់អី រឹងតែម្តងក្នុងប្រាសាទ ។

បូលី៖ បន្ទាយគេហ្នឹង!

យ៉ាំ៖ បន្ទាយវា ។

បូលី៖ ចុះមកកន្លែងនេះសិន មកកន្លែងពិការសិនណា ។

យ៉ាំ៖ មកនៅកន្លែងពិការ ទៅនៅជាមួយតាកេង តាខេង តាសេង សុទ្ធតែកងពល ហើយពូ! ពូស្តែង ។

បូលី៖ ពិការច្រើនទេអ្នកពិការ?

យ៉ាំ៖ ពិការសុទ្ធតែស្រុកភូមិយើងអីក្រចេះនោះក៏នៅហ្នឹងដែរ! មនុស្សរាប់រយអ្នក ។

បូលីៈ សុទ្ធតែពិការហើយណ៎?

យ៉ាំៈ បាទ!

បូលីៈ នៅម្ដុំណាអាហ្នឹង?

យ៉ាំៈ នៅម្ដុំអើអូរដឹកង់! ស្រុកថៃ។

បូលីៈ នៅម្ដុំណាចេះ អូរដឹកង់?

យ៉ាំៈ អូរដឹកង់។

បូលីៈ បើយើងគិតពីដីខ្មែរនៅទល់មុខអី?

យ៉ាំៈ ប្រហក់អាកោង ឯនោះ។

បូលីៈ ខេត្តអី?

យ៉ាំៈ ខេត្តអីណាំយឿននែក! ខេត្តណាងប៊ុន។

បូលីៈ នៅទល់មុខអើ ព្រះវិហារហ្នឹងចឹង?

យ៉ាំៈ ខេត្តណាងប៊ុន។

បូលីៈ ប៉ុនដីខ្មែរយើងនៅទល់មុខអីយើងដីខ្មែរ នៅព្រះវិហារ ឬក៏ឧត្ដរមានជ័យ?

យ៉ាំៈ នៅឧត្ដរមានជ័យ! នៅចំនេះ!

បូលីៈ ភ្នំ១០០៣ ឬក៏១០០១?

យ៉ាំៈ អើ! ខាងនោះក៏១០០៣ ខាងលិចក៏១០០៣តិចហ្នឹង។

បូលីៈ ខាងលិច១០០៣! មានតែជប់ម្ហូ។

យ៉ាំៈ គេមានតែជប់ម្ហូនេះស្រដៀងៗគ្នាហ្នឹង ចុះតិចៗហ្នឹង។

បូលីៈ ស្រែព្រៃ?

យ៉ាំៈ ស្រែព្រៃ នៅឯនោះទៀត។

បូលីៈ នៅខាងលិចទៀត។ កន្លែងពូនៅម្ដុំណា?

យ៉ាំៈ នៅអីនេះតិច។ អត់ទេ! អីជប់ម្ហូ នៅឯនោះអីលិច អានេះអីកើត។

បូលីៈ កើតទេ!

យ៉ាំៈ ១០០៣នេះ នៅតិចហើយដឹកង់ហើយ អូរខ្សាច់។

បូលីៈ នៅម្ដុំស៊ីងចាន់ទេ?

យ៉ាំៈ បាទ! នៅម្ដុំស៊ីងចាន់នោះ ហើយទៅអាផ្លូវនេះ ទៅ៣ម៉ោងបានដល់ស៊ីងចាន់យើងដើរណ៎។

បូលីៈ ៣ម៉ោងដល់ស៊ីងចាន់?

យ៉ាំៈ បាទ! យើងដើរ ។

បូលីៈ ទៅណា ទៅលិច ឬទៅកើត?

យ៉ាំៈ ទៅថៃវិញ ។

បូលីៈ ប៉ុនឥលូវពូមើលនេះវិញ អានេះប្រកដាំស្រូវ អានេះដបម្ល អានេះក្បាលទន្សោងប៉ុល ពត ទៅ អានេះ៤០ អានេះអូត្រាវ ។

យ៉ាំៈ ៤០នេះខ្ញុំនៅ ។

បូលីៈ ពូនៅ៤០ហ្នឹង?

យ៉ាំៈ បាទ!

បូលីៈ មន្ទីរអ្នកពិការនៅម្តុំណា?

យ៉ាំៈ នេះស្អី!

បូលីៈ នៅចង្កោ! នេះក-៧ ដងទង់ ដាំស្វា ឈូករុន អូរ៥០ ។

យ៉ាំៈ អានេះខ្ញុំនៅ!

បូលីៈ ពូនៅណា ចង្កោ?

យ៉ាំៈ ចង្កោ! ហើយចុះឡើងៗ ហើយអូរ៧នេះ ។

បូលីៈ ពូថាអីកាំកង់អំបាញ់មិញនេះ?

យ៉ាំៈ កាំកង់វានៅឯមុខ ។

បូលីៈ នៅឯមុខណា?

យ៉ាំៈ ជិតនែក ជិតភ្នំនេះ ។

បូលីៈ ហើយពូចង្អុលនេះជិតម្តុំណា? អូត្រាវ ក៏ចង្កោ?

យ៉ាំៈ ដីថៃ! នេះនៅនេះ ។

បូលីៈ នៅកន្លែងនេះ នៅម្តុំនេះ ។

យ៉ាំៈ អានេះគេហៅដុំកង់! អូរមួយ អូរចាប់ខ្លា ។

បូលីៈ អូរចាប់ខ្លា?

យ៉ាំៈ ចុះមកពីចាប់ខ្លា អូរហ្នឹងហើយ អូរដុំកង់ ។

បូលីៈ អាហ្នឹងមន្ទីរពិការហើយហ្នឹង?

យ៉ាំៈ បាទ! ពួកតាហឿន ពួកអីនៅ ដល់ក្រោយមក ដល់តែគេ យួនវាបាញ់កាំភ្លើងផ្លោងហ្នឹង ក៏រត់ទៅនៅចង្កោ ដងទង់ ក-៧នេះ ស៊ីងចាន់នេះ ។

បូលីៈ  នៅចន្លោះនេះ ។

យ៉ាំៈ  ទល់នៅរហូតទៅ ។

បូលីៈ  ចឹងពូនៅមន្ទីរពិញការរហូត?

យ៉ាំៈ  បាទ! នៅមន្ទីរពិការរហូត ដល់នេះទៅ បានខ្មោចបងសែង មកនៅជាមួយអញ ក៏នៅជាមួយ តាពីនទៅជាមួយអីទៅ ។

បូលីៈ  កងពលលេខប៉ុន្មាន?

យ៉ាំៈ  កងពលលេខ៩២០ ។

បូលីៈ  តា០៦?

យ៉ាំៈ  បាទ!  តា០៦  តាពីន  តាអី!

បូលីៈ  តាពីន! គាត់ធ្វើអី?

យ៉ាំៈ  គាត់និរសាធំ ។

បូលីៈ  និរសាធំលេខប៉ុន្មាន?

យ៉ាំៈ  លេខប៉ុន្មានទេ! ភ្លេចភ្លាំងហើយ ។

បូលីៈ  ចឹងតាពីន កូនចៅតា០៦?

យ៉ាំៈ  បាទ!

បូលីៈ  ចឹងមកនៅយ៉ាងម៉េចបើពូពិការហើយ?

យ៉ាំៈ  ខ្ញុំនៅ!

បូលីៈ  ធ្វើទាហានទៀត?

យ៉ាំៈ  អត់ទេ! នៅក្នុងក្រសួងមន្ទីរ ហើយដល់ពេលឈឺគ្រុនអីយប់ព្រលប់អីចឹងទៅហៅគេចឹងណា ហើយមាននេះទៅ ក៏មានទូរលេខគេចុចឡប្តិគេមក ហើយបើថាមិននេះទេក៏មើលទៅចឹងណា ។

បូលីៈ  ចឹងយើងអត់គោវាយទៀតណ៎?

យ៉ាំៈ  អត់ទេ!

បូលីៈ  អត់ទៅវាយទេ ។

យ៉ាំៈ  ទៅដល់នេះក្រោយមក បានគេ ខ្ញុំចេញពីកន្លែងពិការហើយចូលមកកងទ័ពហ្នឹងជាមួយអើ! ពីន នោះក៏នៅវាយផ្តាច់ខ្លួន ផ្តាច់ខ្លួនហើយក៏នៅ បានទៅនៅព្រៃប្រឡាយនោះ ។

បូលីៈ  ពេលដែលតាម៉ុក គាត់វាយចុះមកខាងក្រោយចាប់បាន តំបន់អន្លង់វែងត្រពាំងប្រាសាទ ហ្នឹងណា ពេលហ្នឹងពូចុះមកតាមណា?

យ៉ាំ៖ ខ្ញុំចុះមក! គេដឹកមក ។

បូលី៖ តាមច្រកជាំ ឬក៏ច្រក?

យ៉ាំ៖ ច្រកជាំ ។

បូលី៖ ច្រកជាំឯនោះ នោះទេ?

យ៉ាំ៖ បាទ!

បូលី៖ ជាំគេដឹកមកហើយ ។ មកនៅអូរជើក មកនៅអូរជើកហើយបានមកនៅកងតាពីន ។

យ៉ាំ៖ តា០៥! ហៅមកនៅ ។

បូលី៖ នៅម្ដុំណា?

យ៉ាំ៖ នេះ! ភូមិហ្នឹង ។

បូលី៖ នៅទំនប់ជាប់ហ្នឹងតែម្ដង?

យ៉ាំ៖ ដកមកនៅ! តា០៥ ។

បូលី៖ នៅអូរជើកបានប៉ុន្មានឆ្នាំ?

យ៉ាំ៖ នៅអូរជើកបាន២ ទៅ៣ឆ្នាំហើយ ។ ទៅដល់តា០៥ ដកកហៅមកនៅ ហៅមកនៅនេះក៏មកតាពីនទាំងកងតាពិនទាំងអស់ ហៅមកនៅ ។ ដល់នេះនៅជាមួយគាត់ហ្នឹងឯង ប៉ុន្ដែអត់ទៅណាទៅណីនេះឯង ទៅវាយទៅអីទេ ទៅមើលមីននោះណា ។ ដោយសារមើលមីន យប់ព្រលប់អីទៅដល់នេះ បានអើយ! ផ្ដាច់ខ្លួនទៅបានខ្ញុំទៅនៅអីនោះ ទៅនៅព្រះប្រលាយ ទៅយាមព្រះប្រលាយ ។

បូលី៖ អាពេលផ្ដាច់ខ្លួនឆ្នាំ៩៨នេះ នោះ?

យ៉ាំ៖ បាទ! ផ្ដាច់ខ្លួនហើយ ទៅយាមព្រះប្រឡាយ កាំភ្លើងទៅយាមគេបើក ឲ្យកាំភ្លើងមួយដើម ។

បូលី៖ យាមអីគេ?

យ៉ាំ៖ យាម! ដូចជាយាមនេះចេញចូលកុំឲ្យនេះវាខ្សែរយៈ វាទៅបន្ទប់ទៅវា ដល់យាមទៅ គេហៅថាយាមដូច កុងត្រូលយើងនោះ យើងនៅក្នុងភូមិសាស្ត្រយើង ក្នុងភូមិសាស្ត្រយើង គ្នាយើង ៤ ទៅ១០នាក់ក៏ទៅនៅហ្នឹងឯង ទៅនៅ ។

បូលី៖ កាលដែលតាម៉ុក ហើយប៉ុល ពតវាយគ្នា?

យ៉ាំ៖ កាលតាម៉ុក ហើយប៉ុល ពតខ្ញុំទៅយាមនោះ ។

បូលី៖ យាមឲ្យនរណាគេ ឲ្យតាម៉ុក ឬខាងប៉ុល ពត?

យ៉ាំ៖ ខាងហ៊ុនសែន ។

បូលី៖ ខាងហ៊ុន សែន?

យ៉ាំ៖ បាទ!

បូលី៖ ហើយកាលហ្នឹងនេះ យើងមិនទាន់ចុះចូលទេណា?

យ៉ាំ៖ មិនទាន់ចុះចូលទេ ប៉ុនតម្រូវបើខាងតាម៉ុកអេ៎! ខ្ញុំមិនទាន់មកពីនោះទេ ខ្ញុំមិនទាន់មកពីអូរស្វាយទេ?

បូលី៖ អូស្វាយ!

យ៉ាំ៖ បាទ! ពួកនេះគេទៅព្រះវិហារអស់ហើយ ពួកពូនោះៗ ពួកដែលនៅប្រាសាទព្រះវិហារក៏គេទៅព្រះវិហារអស់ហើយ ចឹងណាបានគេត្រៀម! អាអ្នកនៅក្រោយនោះ ពួកខ្ញុំការពារមីងៗត្រៀមនេះ ។

បូលី៖ តា០៥ស្លាប់នៅពេលហ្នឹង?

យ៉ាំ៖ នៅ! គាត់ហ្នឹងត្រៀមដើរតាមផ្លូវភ្នំនោះ ។ ចឹងហើយបានគេស្ទាក់នោះ ។

បូលី៖ ពីណាគេស្ទាក់?

យ៉ាំ៖ ពួកតាម៉ុក ពួកអីហ្នឹង! សម្លេះចោល ។

បូលី៖ ស្ទាកចាប់តា០៥?

យ៉ាំ៖ បាទ! ចេញល្បិចគេ មកៗ ទៅដល់គេទាន់ក៏គេដោក់ទៅ ។

បូលី៖ ពីណាចាញ់គេ?

យ៉ាំ៖ តា០៥ ។

បូលី៖ ល្បិចពីណាគេ?

យ៉ាំ៖ ល្បិចតាម៉ុក ។

បូលី៖ គេថាម៉េច? គេប្រើល្បិចយ៉ាងម៉េច?

យ៉ាំ៖ ល្បិចថាយើងនេះ សម្រុះសម្រួលគ្នាហើយ ហើយតា០៥ល្បិចគាត់ពីនោះមក ។ គេដឹងហើយល្បិចអីនោះ គេចុះចូលៗកងពលៗ គេចុះចូលត្រូវរូវគ្នាហ៊ុនសែន ចឹងបានថាគេ សម្លេះចោល ។

បូលី៖ បានន័យថាកូនចៅតា០៥ ទៅចុះចូលអស់ហើយ?

យ៉ាំ៖ បាទ!

បូលី៖ ប៉ុន្តែអារឿងគេសម្លាប់តា០៥ មកពីតាម៉ុក ឯងតា០៥សម្លាប់សុន សេនទេអី?

យាំុះ	អត់ទេ! រឿងហ្នឹង ហើយសុន សេនហើយ ស្អីៗសុទ្ធដៃដើងគេហើយ ។

បូលីះ	ដៃដើងនរណាគេ?

យាំុះ	ដៃដើងតាម៉ុក ហើយឆ្អិនហើយរៀន នៅស្រុកយួនតាម៉ុក ។ រឿងខ្មែរយួននេះអត់នេះទេ សេ-អ៊ី-អា យួននេះ ប៉ុន្មានឆ្នាំហើយតាម៉ុក ។

បូលីះ	តាម៉ុកក្រែងឈ្មោះជាមួយយួនហេ៎?

យាំុះ	ឈ្មោះពិតមែន! ប៉ុន្តែគាត់ទៅ នៅស្រុកយួនរៀនសេ-អ៊ី-អា យួនប៉ុន្មានឆ្នាំ ។

បូលីះ	ពីអស្គាល់តាម៉ុកទៅរៀននៅយួន?

យាំុះ	តាំងពីនៅតូច! មិនស្គាល់តាម៉ុក?

បូលីះ	ខ្ញុំទើបតែឮទី១តាម៉ុកតៅរៀននៅស្រុកយួន ។

យាំុះ	តាម៉ុក សេ-អ៊ី-អាយួនហ្នឹង ។ ចឹងបានសម្លាប់បណ្តើរៗ ដល់ស៊ីខ្មែរដោ ដល់តែគេធ្វើខ្លាំង គាត់អត់ហានទេ ។ ឃើញទេខ្ញុំអើកាលនៅលើភ្នំ១០០១ ដកកាំភ្លើងខ្ញុំ ដឹងហើយដឹងថាតាម៉ុក ហើយ មករៀន១០០៣នេះខ្ញុំមករៀនហ្នឹង គាត់ថាគាត់កាន់ខ្មែរគោមួយ មួយចន្ទាយដាក់ឯង កាំបិតផ្គាក់លាក់ចោល តោះទៅទៀត ។ ខ្ញុំមកជាមួយពូស្តែងពូអី ទាំងអស់គ្នាខ្ញុំរៀន មួយ អាទិត្យ ដល់តែនេះ គ្រាន់តែរៀនចប់ហើយគាត់ស្លៀកពាក់អា(ស្តាប់ពុំបាន) ដល់នេះចូលរៀន បានស្លៀកពាក់ធម្មតា ។ អត់មានថានេះទេ ដល់ដាច់ ដាច់នៅនេះព្រះប្រឡាយ ដើមប្របក់ ដើរចុះដើរឡើងបញ្ហា ។

បូលីះ	បញ្ហាអីគេ?

យាំុះ	បញ្ហា! អាត្រាក់រុញដីនោះ ។ ខ្ញុំទៅក្នុងហើយ ឮថាតាម៉ុកនោះដាច់ជើង ចឹងដាច់ក៏ដាច់ទៅ ។ កាលមុននៅមិនបានទេ នៅ១០០១ គេធ្វើខ្លាំងអត់ហានទេ គាត់ថាកងអាណានេះ! កាលនោះ ខ្ញុំនៅជាមួយកងបងយិន វរសេនាធំយិន ។ កងអាណានេះ កងអាយិនណា! ខ្ញុំមានទៅខ្លាចស្អី គ្នា៣ទៅ៤នាក់ផង ហើយ ។ ហេ៎ មកដល់នេះកាំភ្លើងមក កាំភ្លើងមកនេះ យកទៅ បាញ់ស្មា បាញ់ទោចនេះយួនឡើងយួនអីតាម ព្រិចតាមអី ពីណាមិនយក ។ ទេដកកាំភ្លើង ហើយបងឯង ធ្វើស្អីហ្នឹង ដក់កាំភ្លើង ទេអញកុងត្រូល អញនៅយាមកុងត្រូល តាឯងដកកាំភ្លើងយកបាល់ ទៅ ។

បូលីះ	យកបាល់តយ៉ាងម៉េច?

យាំុះ	បាញ់! យកឲ្យទុក(ស្តាប់ពុំបាន)ឲ្យខ្ញុំ អត់ហានទេ ។

បូលីះ	១០០១ហេ៎?

យ៉ាំៈ បាទ!

ប៊ូលីៈ អូរចឹងពូធ្លាប់នៅ១០០១ដែរចឹង?

យ៉ាំៈ ធ្លាប់នៅ១០០១,១០០២ហែរចឹង, ១០០៣ ទាល់តែប្រែកស្រូវហើយទៀត ។

ប៊ូលីៈ ចឹងបានន័យថា ពូបែក១០០១ ពូមកនៅនេះសិន?

យ៉ាំៈ ខ្ញុំ! ពេលបែក៧៩នេះហើយ ខ្ញុំវាយឯក្នុងនោះ វាយឯក្នុងនោះឆ្នាំអើ! ៧៩,៨០ បានខ្ញុំឡើងមកលើនោះ ។

ប៊ូលីៈ ១០០១?

យ៉ាំៈ បាទ! ឡើងលើភ្នំហើយទៅក្នុងនោះវិញទៀត ។

ប៊ូលីៈ ទៅមកៗ!

យ៉ាំៈ បាទ! ទៅមកៗហ្នឹង ។

ប៊ូលីៈ មិនមែននៅជាប់ក្នុងរហូតទេ?

យ៉ាំៈ បាទ! ទៅមកៗអីវ៉ាន់អី ខ្ញុំនៅលើភ្នំនោះ!

ប៊ូលីៈ អត់ទាន់ការទេកាលនោះ?

យ៉ាំៈ នៅ!

ប៊ូលីៈ ការនៅណាវិញការ?

យ៉ាំៈ ការហើយ នៅឯគ-៧ ។

ប៊ូលីៈ ការនៅគ-៧ហ៎?

យ៉ាំៈ បាទ!

ប៊ូលីៈ គ-៧ចង្កក?

យ៉ាំៈ ចង្កក ។

ប៊ូលីៈ នឹកឃើញយ៉ាងម៉េចបានការពូ?

យ៉ាំៈ គេបងប្អូន បង្ខំឲ្យការទៅ បើមិនការគឺវាទៅព្រៃហើយ ។ ខ្ញុំគេមកយកប៉ុន្មានដងហើយ ហើយនេះចប់មានបណ្ដូរការបណ្ដូរអី បានគេអត់មក កុំអីទៅព្រៃបាត់ទៀត ។ រៀនចេះចប់ក៏ចូលស្រុកចូលភូមិគេវិញ ។

ប៊ូលីៈ ខ្ញុំដូចជាមានតែប៉ុនហ្នឹងទេពូ ចង់សួរលេងជាមួយពូណា៎ ។ អរគុណពូដែលចំណាយពេល ។

យ៉ាំៈ បាទ!

«ចប់»